ខ្ញុំចង់ដឹង

# អេស៊ីប សម័យ ព្រះចៅ ផារ៉ាអុង



និពន្ធដោយ
Madeleine Michaux

SIPAR

Scanned by CamScanner

ការបោះពុម្ពផ្សាយច្បាប់ដើមក្រោមចំណងជើងថា
L'Égypte au temps des Pharaons © Éditions MILAN 2000 France
ការបោះពុម្ពផ្សាយជាភាសាខ្មែរ : © Éditions SIPAR 2003
Scanned by CamScanner

SIPAR

## ខ្ញុំចង់ដឹង

00010333
HUN SEN LIBRARY



# អេស៊ីប សម័យព្រះចៅ ផារ៉ាអុង

**និពន្ធដោយ Madeleine Michaux**
**ប្រែសំរួលដោយ ស៊ុនហេង ម៉េងឈាង**

**ប្រធានក្រុមសៀវភៅ :** ស៊ុនហេង ម៉េងឈាង - **ជំនួយការបោះពុម្ពផ្សាយ :** លឹម សន្តិភាព
**ទទួលខុសត្រូវបោះពុម្ពផ្សាយ :** Héloïse TISSOT - **ជំនួយការរចនាទំព័រ :** យ៉ែម ខេមចិត្តនា
**គណៈកម្មការអំនាន :** ខោល ភុន, បេ ពុច
**កំនែអក្ខរាវិរុទ្ធ :** ហុក សាពាប់, នេត សុគន្ធា (អង្គការស៊ីប៉ា)

សៀវភៅនេះ បានទទួលការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ
**៧៨៦ អយក.ប្រក.** ចុះថ្ងៃទី ០៨ សីហា ឆ្នាំ ២០០៣ ដើម្បីអោយបោះពុម្ពផ្សាយ
សំរាប់ប្រើប្រាស់ជាសៀវភៅអានបន្ថែម នៅតាមសាលារៀនចំនេះទូទៅ។

Scanned by CamScanner

# មាតិកា

សេចក្តីផ្តើម .................................... 4–5

**វាលលំហសំបូរទៅដោយ...រឿងនិទាន**

- អេស៊ីប នៅឆ្ងាយ នៅជិត .................................... 6–7
- គ្មានទន្លេនីល គ្មានអេស៊ីប .................................... 8–9
- ក្លាយជាស្ត្រីប រស់ដោយការសរសេរ .................................... 10–11
- ព្រះចៅ ផារ៉ាអុង ជាអាទិទេព ជាស្តេចផ្តាច់ការ .................................... 12–13
- បដិមាព្រះអាទិទេពយាងចេញពីព្រះវិហារ .................................... 14–15

**ពីអ្វីជាប្រចាំថ្ងៃ ទៅអ្វីជាអមតៈ**

- ពពួកអាទិទេព និងពពួកមនុស្ស .................................... 16–17
- ជនជាតិអេស៊ីបខ្វាយខ្វល់នឹងសេចក្តីស្លាប់ .................................... 18–19
- សាងសង់ដើម្បីអោយនៅឋិតថេរ តែមិនមែនសំរាប់ទាំងអស់គ្នាទេ .................................... 20–21
- គួរ និងធ្លាក់ពីការពិត .................................... 22–23



Scanned by CamScanner

- អាថ៌កំបាំងនៃអក្សររូប ........................................ 24–25
- ដំនើរនៃពេលវេលា ........................................ 26
- ប្រទេសអេស៊ីបនៅស.វ.ទី៣ មុនគ.ស. ........................................ 27

## អេស៊ីប និងយើង

- ដើរតាមដានអេស៊ីប ........................................ 28–29
- ប្រវត្តិសាស្ត្រនៅក្រោមខ្សាច់ ........................................ 30–31

## សាកល្បងរកចំលើយ ........................................ 32






Scanned by CamScanner





# យើងមិនមែនជាទាយាទនៃអរិយធម៌អេស៊ីបទេ

ក្នុងកាលដ៏យូរលង់មកហើយ អរិយធម៌អេស៊ីបបុរាណបានរីកចំរើនរុងរឿងនៅតាមដង
ទន្លេនីល។ អរិយធម៌នេះមានអាយុតាំងពីឆ្នាំ ៣០០០ មុនគ.ស. រហូតដល់ដើមគ.ស.។
ផារ៉ាអុងជាងាររបស់ព្រះរាជា។ សំណង់ធំៗ មានវិហារ និងចេតិយរាងសាជីជ្រុង ហៅថា
ពីរ៉ាមីត។ គេបានបង្កើតអក្សររូប និងសាសនា ដែលមានអាទិទេពនិងទេវីជាច្រើនដូចជា
អូស៊ីរីស(Osiris) អ៊ីស៊ីស(Isis) សេត(Seth) ហូរុស(Horus)...។

នៅសម័យនោះ អ្នកស្រុកឥណ្ឌាមានអរិយធម៌ល្អតលាស់ហើយ។ គេធ្វើកសិកម្ម ចិញ្ចឹម
សត្វ បង្កើតទីក្រុងធំៗ និងប្រើភាសាសំស្រ្កឹតសំរាប់កត់ត្រាគម្ពីរវេទនៃសាសនា
ព្រាហ្មណ៍។ នៅស.វ.ទី៦ មុនគ.ស. ព្រះពុទ្ធសាសនាបានកកើតឡើង និងបានត្រូវ
ផ្សព្វផ្សាយនៅក្នុងនិងទៅក្រៅឥណ្ឌា។

នៅសម័យនោះដែរ ជនជាតិចិនក៏បានបង្កើតអរិយធម៌រុងរឿងមួយទៀត នៅតាមដងទន្លេ
លឿង។ គេបានកសាងមហាកំពែងសំរាប់ធ្វើជារបងការពារប្រទេស ដាំដំនាំផ្សេងៗ ធ្វើ
ស្រែ...។ គេអនុវត្តលទ្ធិខុងជឺ ធ្វើសក្ការៈដូនតា និងបង្កើតអក្សរចិនបុរាណ។

ចន្លោះឥណ្ឌានិងចិន មានជនជាតិខ្មែររស់នៅ។ នៅដើមគ.ស. ខ្មែរបានបង្កើតនគរភ្នំ
ដែលជារដ្ឋខ្មែរដំបូង និងទទួលឥទ្ធិពលពីឥណ្ឌា។ ចុះហេតុអ្វីយើងស្វែងយល់ពីអេស៊ីប?



ពីរ៉ាមីតនៅអេស៊ីប



ប្រហែល៤០០០ឆ្នាំ
ក្រោយមក ព្រះបាទ
សូរ្យវរ្ម័នទី២ សង់
ប្រាសាទអង្គរវត្ត
នាស.វ.ទី១២។

Scanned by CamScanner

# ក្តីផ្តើម



## ស្នាមអរិយធម៌អេស៊ីបធ្វើអោយយើងរំភើប

វិហារ ពីរ៉ាមីត ផ្នូរសព រឺសាកសពម៉ូមី បានធ្វើអោយយើងចាប់អារម្មណ៍ដោយសារទំហំដ៏ស្កឹមស្កៃរបស់វា និងពីព្រោះវាបង្ហាញពីចំនេះដឹងនិងបំនិនប្រសប់របស់ស្ថាបត្យករ សិប្បករ រឺបព្ជិត ដែលជាអ្នកអប់សាកសពមិនអោយរលួយ។ យើងយល់ឃើញថា ស្លាកស្នាមទាំងអស់នៃអរិយធម៌នេះ ដែលបានបាត់បង់ទាំងស្រុងទៅហើយនោះ មានសោភណភាពល្អណាស់។



សាកូផាស (sarcophage) ប្រែថា មឈូស តែជាភាសាក្រិចមានន័យថា «អ្នកស៊ីសាច់»។ ចំពោះពួកអេស៊ីប ពាក្យនេះមានន័យថា «អ្នករក្សាទុកពួកគេអោយនៅគង់វង្ស»។

## សរុបសេចក្តីទៅ ពួកអេស៊ីប ក៏ដូចយើងដែរ

គេធ្វើការដើម្បីរស់ តែក៏ចេះរកពេលកំសាន្តដែរ។ គេគិតទុកមុនពីអ្វីដែលនឹងកើតឡើងក្រោយពេលស្លាប់ទៅ។ ស្រីៗចូលចិត្តភាពស្រស់ស្អាត ប្រុសៗចង់បានការងារល្អៗ ហើយជួនកាលកុមារតូចៗមិនរៀនមេរៀនដែរ។ អ្នកដែលនឹងក្លាយជាស្ត្រីបដឹងថាគេនិងស្ថិតនៅជាអមតៈដោយសារអត្ថបទពួកគេ។




សាស្ត្រាចារ្យអេស៊ីប ពុំដាក់ពិន្ទុដូចនេះទេ!!! តែពួកគាត់កែដោយប្រើទឹកខ្មៅក្រហម។

Scanned by CamScanner

# អេស៊ីប នៅឆ្ងាយ នៅជិត

ប្រទេសអេស៊ីបស្ថិតនៅប៉ែកខាងលិចឆៀងខាងជើងនៃប្រទេសកម្ពុជា ចំងាយប្រហែល ៧ ០០០គម ពីប្រទេសកម្ពុជាតាមផ្លូវអាកាស។ ដើម្បីធ្វើដំនើរទៅកាន់ប្រទេសនោះ គេត្រូវជិះយន្តហោះ រឺកប៉ាល់ទឹក។ ប៉ុន្តែទេសភាព និងឧតុនិយមនៃប្រទេសនោះខុសគ្នាខ្លាំងពីទេសភាព និងឧតុនិយមនៃប្រទេសកម្ពុជា។

### សំណាញ់ផឹងទេថា

**ស្រូវសាលីក្នុងវាលលំហ!**

ដោយសារអេស៊ីបសំបូរភោគទ្រព្យកសិកម្ម ជនជាតិផ្សេងៗបានចូលមកដណ្តើមភោគទ្រព្យទាំងនោះ : ពួកហ៊ិចសុសមកពីអារ៉ាប៊ី(រវាង ១៦៥០ មុនគ.ស.) ពួកអាស៊ីរីមកពីតំបន់មេសូប៉ូតាមី(រវាង ៦៦០ មុនគ.ស.) ពួកពែក (រវាង៥២៥ មុនគ.ស.) ពួកក្រិច(៣៣២ មុនគ.ស.) ពួករ៉ូម(៣០ មុនគ.ស.)។ ក្រោយមក បារាំងបានជីកព្រែកស៊ុយអេ :បន្ទាប់មក គេអាចធ្វើជំនួញជាមួយបួពាំប្រទេស ដោយពុំចាច់ធ្វើដំនើរព័ទ្ធទ្វីបអាព្រិចឡើយ។

## នៅចុងម្ខាងទៀតនៃសមុទ្រមេឌីទែរ៉ានេ

ឧបមាថាយើងមានចតុកោណកែងធំមួយ។ ខាងជើងនិងខាងលិចមានទ្វីបអឺរ៉ុប ខាងកើតមានទ្វីបអាស៊ី និងខាងត្បូងមានទ្វីបអាព្រិច : ចតុកោណ-កែងនោះ គឺជាសមុទ្រមេឌីទែរ៉ានេ។ ប្រទេសអេស៊ីបស្ថិតនៅទ្វីបអាព្រិច... តែនៅជាប់ទ្វីបអាស៊ី។ អេស៊ីបនៅមិនឆ្ងាយពេកទេពីប្រទេសក្រិច ដែលជាផ្នែកមួយនៃទ្វីបអឺរ៉ុប។

## អេស៊ីបជាផ្នែកមួយនៃវាលខ្សាច់សាហារ៉ា

ដោយសារទីតាំងដូចនេះ ប្រទេសអេស៊ីបមានអាកាសធាតុក្តៅជានិច្ច និងមានភ្លៀងធ្លាក់មិនញឹកញាប់ទេ។ គេឃើញមានតែវាលខ្សាច់ ផ្ទាំងថ្ម និងផ្នូរល្បាក់ធំធេង ដែលគ្របដណ្តប់ផ្ទៃដីមួយភាគធំ។ ប៉ុន្តែកាលពីមុន វាមិនដូចនេះទេ។ ក្នុងអតីតកាលដ៏យូរលង់មកហើយ វាលខ្សាច់សាហារ៉ាមានអាកាសធាតុសើម និងមានព្រៃឈើ។ ជនជាតិអេស៊ីបដើម ប្រហែលជាបានស្គាល់ព្រៃឈើទាំងនោះ។ ៤ ០០០ឆ្នាំ មុននេះ វាលលំហបានលាតសន្ធឹងរហូតដល់សមុទ្រមេឌីទែរ៉ានេ និងនៅទិសខាងកើត រហូតដល់សមុទ្រក្រហម។ គេអាចធ្វើដំនើរតាមសមុទ្រ រឺតាមក្បួនទូរចរកាត់វាលលំហ។ ក្នុងអតីតកាលក៏ដូចក្នុងបច្ចុប្បន្នកាលនេះដែរ គេអាចរស់នៅក្នុងវាលខ្សាច់បាន ប្រសិនបើមានប្រភពទឹក!



នៅតាមចេតិយ សត្វស្វាំងឃ្លាំមើលវាលខ្សាច់។

Scanned by CamScanner

## អេស៊ីបជាទីប្រជុំបមួយ

គេបានឃើញជនបរទេសជាច្រើនមកពីអាព្រិច អាស៊ី រឺអឺរ៉ុប ឆ្លងកាត់ អេ–ស៊ីបជាហូរហែ។ អ្នកខ្លះបានទៅតាំងនៅតំបន់នោះ ជួនកាលដោយទទួលការបង្ខិតបង្ខំនាពេលក្រោយសង្គ្រាម រឺក្រោយការរាតត្បាតពីអ្នកជិតខាង ហើយជួនកាលក៏ដោយសន្តិវិធីផងដែរ។ ប៉ុន្តែតាំងពីយូរយារមកហើយ ជនជាតិអេស៊ីបបាននាំវត្ថុធាតុដើម លោហធាតុមានតំលៃគ្រឿងទេស រឺទាសកចូលមកពីក្រៅតាមផ្លូវសមុទ្រ រឺតាមផ្លូវដីកាត់វាលខ្សាច់។

## អឺចឹង អេស៊ីបជាអឺរ៉ុបខ្លះដែរ

ឧទាហរណ៍ដូចជា ក្លេអូប៉ាតមិនមែនជាជនជាតិអេស៊ីបសុទ្ធទេ តែព្រះនាងជាជនជាតិក្រិច! ហើយដូនតារបស់ព្រះនាង ដែលជាជនជាតិក្រិចដែរនោះ បានសោយរាជ្យសម្បត្តិនៅអេស៊ីបចាប់ពីឆ្នាំ ៣៣២ មុនគ.ស.។ បន្ទាប់មកប្រទេសអេស៊ីបធ្លាក់ទៅក្រោមអំនាចរ៉ូម ដូចតំបន់នៅជុំវិញសមុទ្រមេឌីទែរ៉ានេទាំងមូលដែរ។

### ទីប្រជុំបនៃខ្យល់បក់

នៅខែ មករា ខ្យល់បក់រុញច្រាននាវាពីប្រទេសអារ៉ាប៊ី តំរង់ឆ្ពោះទៅប្រទេសអេស៊ីប។
នៅខែ កក្កដា ខ្យល់បក់មកពីសមុទ្រមេឌីទែរ៉ានេ : គេអាចចេញមកវិញ! ដូចនេះ គេអាចធ្វើជំនួញតាមសមុទ្រដោយងាយ ដូចជា ជាមួយប្រទេសផេនីស៊ី(លីបង់) ជាដើម។

### វាលឈាំហាមួយ

ជាមធ្យម នៅប្រទេសអេស៊ីប ភ្លៀងធ្លាក់តិចជាង៥សម ក្នុងមួយឆ្នាំ។ នៅក្រុងភ្នំពេញ មានភ្លៀងធ្លាក់ជាមធ្យម១៣៧សម ក្នុងមួយឆ្នាំ។

**ពាក្យ** ព្រែកជីកស៊ុយអេ : ព្រែកជីកសំរាប់នាវាចរណ៍ ប្រវែងសរុប១៩៥គម ជីកពីឆ្នាំ ១៨៥៩ដល់ឆ្នាំ ១៨៦៩ ហើយភ្ជាប់សមុទ្រក្រហមទៅសមុទ្រមេឌីទែរ៉ានេ។




នៅជុំវិញសមុទ្រមេឌីទែរ៉ានេ នៅពុំទាន់មានព្រំដែនទេ... ប៉ុន្តែគេនាំគ្នាសំលឹងមើលទៅអេស៊ីប។


Scanned by CamScanner

# គ្មានទន្លេនីល គ្មានអេស៊ីប

នៅសតវត្សទី៥ មុនគ.ស. ជនជាតិក្រិចម្នាក់ឈ្មោះ ហេរ៉ូដូត (Hérodote) បានសរសេរថា អេស៊ីបជា *«អំនោយទាននៃទន្លេនីល»* ។ តាំងពីមុនសម័យនោះម្ល៉េះ (១២០០ឆ្នាំ មុនគ.ស.) ចំរៀងអេស៊ីបមួយបទបានរៀបរាប់រឿងនេះស្រេចទៅហើយ : *«កាលណាវាហូរ ជីវិតរាយត្រេកអរ ពោះមិនមានកង្វល់ឡើយ»* ។



### សំលាញ់ដឹងទេថា

**អាទិទេពទន្លេនីល**

ចំពោះជនជាតិអេស៊ីប ទន្លេនីល ដែលជាភាគសំខាន់បំផុតនៃជីវិតរបស់ពួកគេ ជាអាទិទេពមួយអង្គមាននាមថា ហាពី(Hapy)។ ខាងលើនេះជារូបព្រះអង្គកំពុងថ្វាយផ្កាឈូកពិសិដ្ឋ។ ពោះព្រះអង្គតូច និងរាងមូលជានិមិត្តរូបនៃវិបុលភាព។

## វាលលំហ ដែលមានទឹក មិនមែនជាវាលលំហឡើយ

ទន្លេដ៏ធំមួយឈ្មោះទន្លេនីលហូរកាត់វាលលំហអេស៊ីប ពីត្បូងចុះទៅជើង។ ទន្លេនេះមានប្រភពហូរចេញពីកន្លែងមួយជិតបឹងវិចតូរ្យ៉ា(Victoria) នៅតំបន់អេក្វាទ័រ ហើយហូរចំងាយ៦ ៧០០គម រហូតទៅដល់សមុទ្រមេឌីទែរ៉ានេ។ នៅតំបន់នោះ វាបង្កើតបានជាដីសណ្តដ៏ធំធេងមួយ។ អេស៊ីបជាអ្នាស៊ីសមួយយ៉ាងវែង ពោលគឺកន្លែងមានទឹក ដែលធ្វើអោយវាលខ្សាច់មានជីជាតិ ហើយដែលពុំអាចកើតឡើងបានទេ បើគ្មានទន្លេនីលនោះ។

## រដូវអាឃីត រដូវសេម្ម

អេស៊ីបរស់នៅតាមចង្វាក់នៃការឡើង រឺការស្រកនៃទឹកទន្លេនីល។ ចាប់ពីខែ កក្កដា ដល់ ខែ កញ្ញា ទឹកឡើងលិចជ្រលង លើកលែងតែភូមិអ្នកស្រុកប៉ុននោះ ដែលគេបានស្ថាងសង់លើទីទួល : គឺជារដូវអាឃីត។ បន្ទាប់មក



Scanned by CamScanner

ទឹកទន្លេនីលក៏ស្រកចុះ ពីព្រោះនៅតំបន់អេត្យូពីរដូវភ្លៀងបានចប់ហើយ។ ប៉ុន្តែទឹកជំនន់បានបន្សល់ទុកដីល្បាប់ពណ៌ខ្មៅសំបូរទៅដោយជីជាតិ។ នៅខែ តុលា គេអាចសាបព្រោះបាន។ គេប្រមូលផលនៅរដូវសេម្ហ(ពីខែ មករា ដល់ ខែ មិថុនា)។

## ទឹកឡើងលុបបំបាត់ព្រំដី អ្នកវាស់ដីធ្វើការវាស់វែងសាជាថ្មី

ជារៀងរាល់ឆ្នាំ ទឹកឡើងតែងនាំដីល្បាប់មកចាក់រាយបំពេញ ធ្វើអោយស្នាមព្រំស្រែចំការរលុបបាត់អស់។ ជារៀងរាល់ឆ្នាំដែរ ពួកស្ត្រីបអ្នកវាស់ដីតែងតែវាស់អួសខ្សែព្រំប្រទល់ស្រែចំការជាថ្មីឡើងវិញ។ ពួកគេចេះគណនារកផ្ទៃរបស់ចតុកោណកែង ចតុកោណព្នាយ រីត្រីកោណ។ ជួនកាលគេត្រូវសង់ទំនប់ ប្រលាយ និងអាងទឹក។

## ទន្លេនីល ជាប្រភពនៃជីវិត

ដោយសារទន្លេនីល ជនជាតិអេស៊ីបអាចដាំស្រូវសាលី អក បន្លែ ទំពាំងបាយជូរ ដើមលម៉ើ ដើមឡាំងសំរាប់យកសរសៃត្បាញកំនាត់សំពត់។ ពួកគេចិញ្ចឹមគោ លា ចៀម ពពែ បក្សីស្រុក(តែមិនចិញ្ចឹមមាន់ទេ!)។ នៅតាមមាត់ទន្លេ គេអាចបរបាញ់សត្វស្លាប ដំរីទឹក និងនៅតំបន់ខ្លះ គេអាចចាប់ក្រពើបានទៀតផង។ ទន្លេនីលក៏ផ្តល់ត្រីអោយផងដែរ ហើយគឺនៅតាមមាត់ទន្លេនេះឯង ដែលគេឃើញមានដុះដើមប៉ាពីរុសសំរាប់យកទៅធ្វើជាក្រដាស។



**មានឆ្នាំអាក្រក់ដែរ!**
ជួនកាល ទឹកទន្លេនីលឡើងតិចពេក មិនគ្រប់គ្រាន់ដើម្បីធ្វើអោយកសិកម្មទទួលបានផលល្អទេ ហើយប្រទេសអេស៊ីបក៏មានការអត់ឃ្លាន(ស្ទើរតែជាគ្រោះទុរ្ភិក្ស)។ ព្រះចៅ ផារ៉ាអុង អង្គឯងទ្រង់កើតទុក្ខ : *«បេះដូងខ្ញុំកើតទុក្ខព្រួយខ្លាំងណាស់ ព្រោះទឹកទន្លេនីលពុំបានឡើងតាមពេលវេលាអស់រយៈពេល៧ឆ្នាំមកហើយ។ គ្រាប់ធញ្ញជាតិមិនសំបូរទេ...ហើយគេមានអ្វីៗតិចតួចណាស់សំរាប់ហូប... អ្វីៗដែលមានជីវិតតែងមានទុក្ខ»*។ (ព្រះចៅ ផារ៉ាអុង ឌ្យោស៊ែ រវាងឆ្នាំ ២៦០០ មុនគ.ស.។)

**ពាក្យ**

អ្នកវាស់ដី : អ្នកវាស់ដីស្រែចំការ។ កាលពីដើម គេវាស់ដីគិតជាអាកប៉ង់ (ពី២០ ទៅ៥០អា ទៅតាមប្រទេស) មិនគិតជាម៉ែតការេទេ។

ប៉ាពីរុស : រុក្ខជាតិម្យ៉ាងដុះនៅដីសណ្តទន្លេនីល។ នៅប្រទេសអេស៊ីប ប៉ាពីរុសអាចប្រើការបានច្រើនយ៉ាងណាស់។ បើគេកាត់វាជាបន្ទះស្តើងៗ គេអាចធ្វើជារមូរក្រដាស។ ចំពោះអ្នកឯកទេសសិក្សាពីអេស៊ីប រមូរប៉ាពីរុស ជា«សៀវភៅ»សំរាប់ស្រាវជ្រាវ។



Scanned by CamScanner

# ក្លាយជាស្រ្គីប រស់ដោយការសរសេរ

ស្រ្គីបជា «អ្នកសរសេរ»។ នៅក្នុងប្រទេសមួយ ដែលមនុស្សភាគច្រើនមិនចេះអាន និងសរសេរ មានតែពួកស្រ្គីបទេ ដែលអាចធ្វើការងាររដ្ឋបាលបាន។ ប្រការនេះធ្វើអោយពួកគេមានអំនាចទូលំទូលាយ។



ស្រ្គីបអង្គុយពែនភ្នែន ដែលគេដាក់តាំងនៅសារមន្ទីរល្លូ ប្រទេសបារាំង។

## ធ្វើជំរឿន ផ្ទៀងផ្ទាត់

ក្នុងរយៈពេល២ឆ្នាំម្តង ពួកស្រ្គីបតែងតែធ្វើការវាស់វែងដីស្រែចំការ ធ្វើបញ្ជីម្ចាស់កម្មសិទ្ធិ រាប់សត្វស្រុក។ ជារៀងរាល់ឆ្នាំ ពួកគេត្រូវព្យាករកសិផល ដើម្បីកំនត់ពន្ធ។ ពួកគេមួយក្រុមៗ មានគ្នា៦នាក់ ក្នុងនោះមានស្រ្គីបម្នាក់ជា «អ្នកកាន់ខ្សែ» និងស្រ្គីបម្នាក់ទៀតជា «អ្នកទាញខ្សែ» ។ ពួកស្រ្គីបទាំងនេះធ្វើការថ្វាយព្រះចៅ ផារ៉ាអុង ដែលជាអ្នកសំរេចថាត្រូវធ្វើអ្វីល្អសំរាប់អេស៊ីប។

## ប្រមូលពន្ធដារ និងពន្ធគយ

ពន្ធដារត្រូវបង់ជាវត្ថុ ដូចជា ស្រូវសាលី គោ-ល-និង-ល-។ នៅពេលប្រមូលកសិផល ពួកស្រ្គីបតែងធ្វើដំនើរទៅដល់ដីស្រែដោយផ្ទាល់ ដើម្បីធ្វើការគណនាពន្ធ ដែលកសិករត្រូវបង់។ អ្នកដែលមិនព្រមបង់ពន្ធ ត្រូវទទួលរងការវាយដំពីសំនាក់ពួកអង្គរក្ស ដែលដើរតាមពួកស្រ្គីប។ គេយកពន្ធដារ ដែលពួកគេប្រមូលបានទាំងអស់ទៅទុកសំរាប់ចិញ្ចឹមពួកមន្ត្រីរាជការ។ ចំនែកនៅតាមព្រំដែនឯនោះវិញ ពួកស្រ្គីបហូតពន្ធគយពីផលិតផល ដែលគេនាំចូលមកក្នុងប្រទេសអេស៊ីប។

### សំណាញ់ដឹងទេថា

**«បណ្ណាល័យធំ» របស់ជនជាតិអេស៊ីប**

គឺដោយសារពួកស្រ្គីបនេះហើយ ដែលយើងបានដឹងខ្លះៗ អំពីអ្វី ដែលជនជាតិអេស៊ីបបានសរសេរ : សំរាំងដំបូន្មានប្រលោមលោក កំនាព្យ វចនានុក្រម ចំរៀងសំរាប់ច្រៀងថ្វាយអាទិទេព«សៀវភៅខ្មោច» រឿងនិទាន។



Scanned by CamScanner

## មិនងាយស្រួលទេ ទំរាំបានធ្វើជាស្គ្រីប !

ដើម្បីក្លាយជាស្គ្រីប គេត្រូវរៀនសូត្រអស់រយៈពេលយូរ។ ស្គ្រីបរៀនអាន រៀនសរសេរ រៀនរាប់ និងត្រូវរៀននៅក្នុងសាលាចំនួន៤ឆ្នាំយ៉ាងតិច ហើយត្រូវរំពាត់ជាញឹកញាប់ : *«គេទាញត្រចៀកក្មេងប្រុស យាវទៅលើខ្នងវា វាស្ដាប់នៅពេលណាដែលគេវាយវា»*។ ប៉ុន្តែបន្ទាប់ពីបានរៀនសូត្រចេះដឹងហើយ គេទទួលការគោរពពីអ្នកដទៃ មិនធ្វើការដោយប្រើកំលាំងកាយឡើយ *«ត្រូវធ្វើជាស្គ្រីបដើម្បីអោយដៃឯងនៅទន់ៗល្អ»* និងទទួលបានប្រាក់បៀវត្សច្រើន។

## វីសៀ(រដ្ឋមន្ត្រី) : «ភ្នែក និងត្រចៀករបស់ផារ៉ាអុង»

នៅថ្នាក់លើខ្ពស់បំផុតនៃឋានានុក្រមពួកស្គ្រីប មានវីសៀ ដែលជាដៃស្ដាំរបស់ព្រះចៅ ផារ៉ាអុង។ រដ្ឋមន្ត្រីគោរពព្រះចៅ ផារ៉ាអុងតែម្នាក់ប៉ុណ្ណោះ ហើយគេមានការទទួលខុសត្រូវធំៗ ដូចជាក្នុងការងារសាធារណៈនានា ពន្ធដារ នគរបាល ការដឹកជញ្ជូន កងទ័ពជាដើម។ រៀងរាល់ព្រឹក គេធ្វើការជាមួយព្រះចៅ ផារ៉ាអុង។

### ឧបករណ៍របស់ពួកស្គ្រីប




### វីសៀល្បីៗ

រដ្ឋមន្ត្រីខ្លះ ដែលនៅតែមានឈ្មោះល្បីល្បាញនៅឡើយមាន ដូចជា ផ្តាហូតិប(Ptahotep) រឺ រ៉ាម៉ូស(Ramose) រឺ ប៉ាសេ (Paser)។ ពួកគេមានគោរមងារជាច្រើន ដូចជា«សេនាជង្រុកខុប» «នាយកលំនៅឋានមហាក្សត្រក្រហម» រឺ «លេខាធិការបេសកកម្មសំងាត់» ជាដើម។

**ពាក្យ**

**សៀវភៅខ្មោច** : សៀវភៅនេះ បានត្រូវសរសេរឡើង សំរាប់ជួយអ្នកស្លាប់ទៅអោយចូលទៅដល់ឋានខ្មោច។

**ឋានានុក្រម** : ការរៀបចំសង្គមមានទំរង់ជា...ពីរ៉ាមីត! នៅខាងក្រោមប្រធាន មានអនុប្រធាន រួចប្រធាន អនុប្រធានតូចៗ តទៅទៀត-ល-។

**ប៉ាពីរុស** (មើលទំព័រទី៩)។


Scanned by CamScanner

# ព្រះចៅ ផារ៉ាអុង ជាអាទិទេព ជាស្ដេចផ្ដាច់ការ

គម្ពីរប៊ីបបានបញ្ជូនពាក្យ «ផារ៉ាអុង» មកអោយយើង។ ពាក្យនេះចេញមកពីពាក្យអេស៊ីប «pir-ô» ដែលមានន័យថា «ផ្ទះធំ» ។

អ៊ីចឹងមែនហើយ ពីព្រោះព្រះរាជា ដែលគ្រងរាជសម្បត្តិនៅប្រទេសអេស៊ីប តែងគង់នៅក្នុងវាំងដ៏ធំមួយ មានរាជបរិវារច្រើន ដែល «អោនក្រាបដល់ដី» នៅចំពោះព្រះភក្ត្រព្រះអង្គ។

## ផារ៉ាអុង ជាព្រះបុត្រា និងជា ព្រះរៀមរបស់ព្រះអាទិទេព

ព្រះចៅ ផារ៉ាអុង ជាបុត្រារបស់អាទិទេពព្រះអាទិត្យរ៉េ(Rê) : ដើម្បីអាចរៀបអភិសេកជាមួយព្រះអង្គម្ចាស់ក្សត្រិយ៍ ដែលនឹងក្លាយទៅជាមាតារបស់ផារ៉ាអុង អាទិទេពព្រះអាទិត្យបានកាឡាខ្លួនជាមនុស្ស ជាព្រះរាជាមុន! ដូចនេះហើយ ផារ៉ាអុងដែលមានរូបរាងជាមនុស្ស ត្រូវគេជឿថាជាបុត្រារបស់អាទិទេពព្រះអាទិត្យរ៉េ។ ព្រះអាទិទេពបានប្រទានរាជបល្ល័ង្គសំរាប់ទ្រង់សោយរាជ្យ នៅអេស៊ីបលើ (ភូមិភាគខាងត្បូង) និងនៅអេស៊ីបក្រោម (ភូមិភាគខាងជើង)។

### សំណាញ់ដឹងទេថា

**ព្រះរាជាទ្រង់គ្រឿង**

ផារ៉ាអុងពាក់គ្រឿងលំអ ដែលជានិមិត្តរូបនៃអំនាចព្រះរាជា : ឈ្សិននៅលើព្រះកេស(មួកឧបនៃអេស៊ីបលើ និងអេស៊ីបក្រោម) ក្បាលពស់វែក ដែលគេបានផ្សាំងរួចសំរាប់អោយចឹកសត្រូវ ពុកចង្កាក្លែងក្លាយ ដែលគេក្រង រាជទណ្ឌ និងរំពាត់។




## ផារ៉ាអុងត្រូវធ្វើអោយមានសុខដុមនៅលើផែនដី

ដោយសារតែផារ៉ាអុងជាតំនាងអាទិទេព ព្រះអង្គក៏ជាម្ចាស់លើបាតុភូតធម្មជាតិ និងឧតុភូតផងដែរ។ ពេលព្រះអង្គចូលទិវង្គត រឺពេលព្រះអង្គមិនបានគោរពក្បួនច្បាប់អោយបានត្រឹមត្រូវនោះ គ្រោះធម្មជាតិអាចកើតមានឡើង : ទឹកទន្លេនីលឡើងតិចពេក រឺឡើងខ្ពស់ពេក ហើយការអត់ឃ្លានក៏កើតមានឡើង។ ដូចនេះហើយ សំរាប់ពួកអេស៊ីប មានព្រះរាជា «ល្អ» គឺពិតជាការសំខាន់ដល់អាយុជីវិត។



Scanned by CamScanner

## «អ្វីៗ ដែលព្រះរាជាបញ្ជា ត្រូវតែសំរេចអោយបាន»

ព្រះចៅ ផារ៉ាអុងដឹកនាំអ្វីៗទាំងអស់ នៅក្នុងប្រទេសអេស៊ីប ដែលបានត្រូវចាត់ចែងទុកជាកម្មសិទ្ធិរបស់ទ្រង់។ ផារ៉ាអុងតាមដានមើលកសិផល បញ្ជាអោយគេបង់ពន្ធ សាងសង់វាំង និងប្រាសាទ ដឹកនាំកងទ័ពការពារប្រទេសជាតិ និងចុះព្រះហស្តលេខាលើសន្ធិសញ្ញា។ ព្រះអង្គក៏ទទួលខុសត្រូវក្នុងការធ្វើអោយមានសណ្តាប់ធ្នាប់ក្នុងសង្គមផងដែរ : ដោយមាន ជំនួយពីរដ្ឋមន្ត្រីនិងពីចៅក្រមជាច្រើនរូប ព្រះអង្គធ្វើអោយមានយុត្តិធម៌នៅក្នុងសង្គម ដែលជួនកាលមិនកើតមានឡើងភ្លាមៗនោះទេ។ គេបានដឹងរឿងរ៉ាវទាំងអស់នេះ តាមរយៈអំនានសៀវភៅប៉ាពីរុស ស្តីអំពីការអង្កេត និងសាលក្រម។



ក្បាំងមុខដែលរកឃើញក្នុងផ្នូររបស់ព្រះចៅ ទូតង់ខាម៉ុន

## ប៉ុន្តែផារ៉ាអុង ក៏ជាមនុស្សដែរ

ផារ៉ាអុងទាំងឡាយត្រូវសិក្សារៀនសូត្រច្រើន ហើយផារ៉ាអុងមួយចំនួនក្លាយជាអ្នកនិពន្ធ : ស្នេព្រូ(Snéfrou)សរសេរសុន្ទរកថា អាខេណាតុន(Akhenaton)ជាទស្សនវិទូនិងជាកវី។ ប៉ុន្តែព្រះចៅ ផារ៉ាអុងក៏មានគុណវិបត្តិដូចមនុស្សឯទៀតដែរ : ជួនកាលផារ៉ាអុងពុំមានសមត្ថភាពដឹកនាំទេ។ ផារ៉ាអុងមួយអង្គ អាចលង់ស្នេហ៍ស្រី ដូចជាព្រះចៅ អាខេណាតុនស្រលាញ់នេហ្វែទីទី(Néfertiti) ដែលមានន័យថា «ស្រីស្អាតមកហើយ»។ ជាញឹកញាប់ រូបព្រះនាងជាមួយស្វាមីនិងបុត្រី បានត្រូវគេឆ្លាក់នៅលើចំលាក់លិប រឺគូរលើផ្ទាំងគំនូរ។

### ដំបូន្មានរបស់ផារ៉ាអុងមួយអង្គចំពោះរាជបុត្រា

*«ត្រូវជាសិល្បករពូកែខាងសំដី ដើម្បីឈានទៅយល់ជ័យជំនះ។ ភាសាជាដាវមុតស្រួចរបស់ព្រះរាជា។ ពាក្យសំដីមានអំនាចខ្លាំងពូកែជាងអាវុធណាៗទាំងអស់... មិនត្រូវកាចទេ ការទប់ចិត្តខ្លួនឯងបាន ជាការប្រសើរណាស់។»*

**ពាក្យ**

គម្ពីរប៊ីប : គម្ពីរសាសនារបស់ពួកជ្វីប និងពួកអ្នកកាន់សាសនាគ្រិស្ត (ព្រះយេស៊ូ)។ នៅក្នុងគម្ពីរនោះ មានរឿងនិទានអំពីការស្នាក់នៅរបស់ពួកជ្វីបក្នុងប្រទេសអេស៊ីប នៅសម័យស្តេចផារ៉ាអុង។

ប៉ាពីរុស (មើលទំព័រទី៩)។

ចំលាក់លិប : ចំលាក់រាក់ៗលេចចេញបន្តិចពីជញ្ជាំង។ គេមិនអាចដើរជុំវិញវាបាន ដូចដែលគេដើរជុំវិញបដិមាទេ។



Scanned by CamScanner

# បដិមាព្រះអាទិទេព យាងចេញពីព្រះវិហារ

ថ្ងៃនេះ ជាថ្ងៃសំខាន់! គឺជាថ្ងៃបុណ្យ អូប៉េ(Opê)។ អាទិទេពអាម៉ុង-រ៉េ (Amon-Rê) ដែលមានព្រះចៅ ផារ៉ាអុង និងអាទិទេពឯទៀតហែហមផងនោះ ទ្រង់យាងឡើងតាមទន្លេនីល។ ១០ថ្ងៃ ក្រោយមក ព្រះអង្គទ្រង់យាងត្រលប់មកវិញ។ អាទិទេពអាម៉ុង-រ៉េ និងព្រះចៅ ផារ៉ាអុង នឹងមានអំនាចខ្លាំងពូកែជាងពេលណាៗទាំងអស់ : អាទិទេព និងព្រះអង្គ នឹងចំរើនបានមហិទ្ធិរិទ្ធិឡើងវិញ។

### ព្រះវិហារ ជាសំនាកពិភពលោក

ដីជារូបភាពនៃដីល្អ និងសំបូរជីជាតិ។ ពិតានជានិមិត្តរូបនៃមេឃ និងផ្កាយ ឯការតែងលំអបរិយាយអំពីការបង្កើតលោក។ ដោយហេតុនោះហើយ ព្រះវិហារជាមធ្យោបាយតែមួយគត់សំរាប់ជួយពួកអាទិទេព ក្នុងការថែទាំពន្លឺ និងជីវិត អោយនៅដាច់ឆ្ងាយពីភាពងងឹត និងពីមរណភាព។






ពួកបព្វជិតនឹងបញ្ចេញបដិមាព្រះអាទិទេពពីលំនៅសំងាត់របស់ព្រះអង្គ។ ព្រះចៅ ផារ៉ាអុង យកតង្វាយជាអាហារទៅថ្វាយ។ ព្រះអង្គ បន្សុទ្ធអាហារដោយប្រើទឹកនិងផ្សែងធូប។



Scanned by CamScanner



គេលើកបដិមាអាទិទេពដាក់លើទូកនៃក្បួនហែ។ បព្វជិតចំនួន៣០អង្គសែងបដិមា។ ពេលសែងចេញមកដល់ក្រៅ ពួកបព្វជិតទាំងនោះជួបអ្នកភ្លេង និងអ្នករាំ ដែលនៅចាំទទួលអបអរការយាងចេញរបស់ព្រះអាទិទេព ដោយរាក់ទាក់បំផុត។

ក្បួនហែទូកអាទិទេព




## ហួសពីព្រំដែននេះទៅ គ្រោះថ្នាក់មានទំហំធំធេង

ព្រះវិហារអេស៊ីបមិនដូចព្រះវិហារខាងគ្រិស្តសាសនាទេ ពួកអេស៊ីបមិនចូលព្រះវិហារ ដើម្បីសូត្រធម៌ឡើយ។ មានតែពួកបព្វជិតនិងព្រះចៅផារ៉ាអុងប៉ុននោះ ដែលជារៀងរាល់ព្រឹក អាចជួយអាទិទេពអោយបង្កើតពន្លឺ និងជីវិតឡើងវិញបាន។



Scanned by CamScanner

# ពពួកអាទិទេព និងពពួកមនុស្ស

ផារ៉ាអុងមួយអង្គៈ
ជាមេបញ្ជិតទាំងអ
ហើយត្រូវការអោយគេ

ជួយ ទើបអាទិទេព ដែលមានចំនួនរាប់រយ អាចទទួលបាន ការគោរពដោយសមសួន។ អាទិទេពទាំងនោះ ដែលអាចប្ដូរ រូបរាង និងឈ្មោះ មានចំនួនច្រើនណាស់ រហូតដល់គេមិន អាចរាប់អស់។

## សំណាញ់ដឹងទេថា

**អាទិទេពតែមួយអី?... បដិវត្តន៍មួយ ដែលមិនបាន ស្ថិតនៅយូរអង្វែង!**

ជាញឹកញាប់ នៅក្នុងតំបន់ណាមួយនៃប្រទេសអេស៊ីប អាទិទេពមួយបានត្រូវគេគោរពលើកតំកើងជាងអាទិទេពឯទៀតៗ។ អាទិទេពរ៉ា និងអាម៉ុង ដែលច្រើនតែនៅរួមគ្នា ទទួលឋានៈខ្ពស់ជាងគេ។ នៅស.វ. ទី១៤ មុនគ.ស. ព្រះចៅផារ៉ាអុង អាខេណាតុន សាកល្បងបង្ខំអោយគោរពអាទិទេពតែមួយ ព្រះនាម អាតុន ប៉ុន្តែជនជាតិអេស៊ីបមិនព្រមទទួលយកទេ។ *«សកលលោក កើតឡើងដោយស្នាព្រះហស្ត ព្រះអង្គ។ បើព្រះអង្គភ្ញាក់ វា មានជីវិត តែបើព្រះអង្គផ្ទំ វា ស្លាប់»*។ ចំរៀងនេះថ្វាយអាទិទេពអាតុន (ព្រះអាទិត្យ)



ថូត

## ភូមិខ្ញុំមានអាទិទេព... និងទេវីរបស់ខ្លួន

តំបន់នីមួយៗ ទីក្រុងនីមួយៗ ភូមិនីមួយ សុទ្ធតែមានអាទិទេពមួយ រឺច្រើនអង្គនៅថ រក្សាការពារ។ ដោយសារអាទិទេពទាំ នោះអាចកាឡាខ្លួនជាសត្វ រឺពាក់កណ្ដាល មនុស្ស ពាក់កណ្ដាលសត្វ គេបានគិតថ អាទិទេពទាំងនោះជាតូតិម ដែលបានរស នៅតាំងពីបុរេប្រវត្តិមកម្ល៉េះ។ ប៉ុន្តែរឿងនេ មិនប្រាកដទេ។

## ដើម្បីអោយអាទិទេព «មើលឃើញ»

គេត្រូវថ្វាយតង្វាយដល់ព្រះអង្គ ធ្វើការបួងសួង អប់ខ្មោចសត្វជាតំនាងព្រះអង្គ ៖ សត្វឆ្មា (ចំពោះអាទិទេពបាស្តេ) សត្វក្ង (អាទិទេពថូត «Thot») មេគោ (អាទិទេពហាទ័រ «Hathor») ស្ទាំង (អាទិទេពហូរុស) ចចក (អាទិទេពអានូប៊ីស) -ល-។ គេក៏អាចសូត្រមន្តអាគមផ្សេងៗ ព្រមទាំងប្រើយ័ន្តគាថាផងដែរ។



បាស្



Scanned by CamScanner

ហូរុស



## ក្នុងអាថ៌កំបាំងនៃវិហារធំៗ

មានតែពួកបព្វជិតនិងផារ៉ាអុងទេ ទើបអាចចូលទៅក្នុងវិហារអាទិទេពសំខាន់ៗបាន ដូចជាវិហារអាទិទេពរ៉ែនៅក្រុងលុកសឺ ផ្ទះ មូត និងរ៉ែនៅក្រុងកាណាក់។ រៀងរាល់ថ្ងៃ ពួកបព្វជិតតែងទៅដាក់ក្រយាស្ងោយថ្វាយបដិមាព្រះអាទិទេព លាងសំអាត និងអុជធូបថ្វាយ។ បដិមាមិនមែនគ្រាន់តែជាបដិមាប៉ុននោះទេ : ព្រះអាទិទេពទ្រង់មកសណ្ឋិតនៅក្នុងនោះ។ ពេលអាទិទេព «សោយ» រួចហើយ គេដកយកក្រយាស្ងោយពីមុខព្រះអង្គទៅដាក់ថ្វាយអាទិទេពបន្ទាប់បន្សំឯទៀតៗ រឺដាក់ថ្វាយបដិមាផារ៉ាអុង។ នៅទីបញ្ចប់ គេយកអាហារនោះ ទៅចែកអោយពួកបព្វជិត និងអ្នកបំរើ។

## ប្រវត្តិក្រៀមក្រំរបស់អាទិទេពអូស៊ីរីស និងអ៊ីស៊ីស

អ៊ីស៊ីស



អាទិទេពអូស៊ីរីសបានត្រូវធ្វើគុតដោយអនុជព្រះអង្គព្រះនាមសេត ដែលមានការច្រណែន។ បន្ទាប់ពីស្វែងរកអស់ពេលយ៉ាងយូរ ទេវីអ៊ីស៊ីសដែលជាមហេសីរបស់អូស៊ីរីស ក៏បានរកព្រះអង្គឃើញ ហើយប្រស់ព្រះអង្គអោយរស់ឡើងវិញ។ ក្រោយមក ហូរុសដែលជាបុត្រារបស់អូស៊ីរីសនិងអ៊ីស៊ីស តាំងចិត្តធ្វើការសងសឹកអោយបិតាខ្លួន។ ទីបញ្ចប់ អាទិទេពទាំងឡាយក៏ចែកសកលលោកអោយសេត និងហូរុសភ្លូតត្រា ចំនែកឯអូស៊ីរីសត្រូវសោយរាជ្យនៅចក្រភពខ្មោច។

### ចំរៀងថ្វាយអូស៊ីរីស

*«ដីនៃភពផែនដី ស្ថិតនៅលើដៃរបស់ទ្រង់ បើទ្រង់កំរើក ផែនដីនឹងញ័រ(...)។ ទ្រង់ជាព្រះបិតានិងមាតារបស់ពួកមនុស្ស ពួកគេរស់នៅដោយសារការដកដង្ហើមរបស់ទ្រង់ ពួកគេស៊ីសាច់ខ្លួនប្រាណរបស់ព្រះអង្គ។»*
(រវាងឆ្នាំ ១៥០០ មុនគ.ស.)

**ពាក្យ**

តូតិម : សត្វ រឺរុក្ខជាតិ ដែលគេបានចាត់ទុកជាជូនតារបស់មនុស្សមួយក្រុម របស់កុលសម្ព័ន្ធមួយ របស់ភូមិមួយ។

ក្ង : បក្សីម្យ៉ាង មានចំពុះវែង ខ្លួនពណ៌ស ក្បាលនិងកន្ទុយពណ៌ខ្មៅ។ ជនជាតិអេស៊ីបយកសត្វនេះធ្វើជាតំនាងថូត ដែលជាអាទិទេពនៃការនិពន្ធ និងមន្តអាគម ជាម្ចាស់ពួកស្មៀន និងជាម្ចាស់នៃរង្វាស់ពេលវេលា។

យ័ន្តគាថា : របស់អ្វីដែលជួយការពារ ជាទូទៅច្រើនជារបស់មួយតូច ដែលគេយកជាប់នឹងខ្លួន។

HUN SEN LIBRARY
R.U.P.P.



Scanned by CamScanner

# ជនជាតិអេស៊ីបខ្វាយខ្វល់នឹងសេចក្ដីស្លាប់

ជនជាតិអេស៊ីបចំនាយពេលវេលានិងពលកម្មច្រើន ក្នុងការរៀបចំជីវិតពួកគេសំរាប់ក្រោយពេលស្លាប់ទៅ។ អ្វីៗដែលយើងដឹងពីពួកគេ បានមកសឹងតែទាំងអស់ពីចេតិយ ដែលជាកន្លែងរស់នៅរបស់អ្នកស្លាប់ និងពីសាកសពម៉ូមី ដែលត្រូវរក្សាវិញ្ញាណក្ខន្ធអោយស្ថិតនៅជាអមតៈ។

## ជីវិតមនុស្សខ្ទីណាស់

ព្រះចៅ ផារ៉ាអុង គ្រួសារព្រះអង្គ ពួកមន្ត្រីនិងបព្វជិតមានសោយ និងហូបចុកបរិបូរ ប៉ុន្តែពួកកសិករក្រីក្រមានការអត់ឃ្លានជាញឹកញាប់។ គេឃើញមានជំងឺនិងគ្រោះថ្នាក់កើតឡើងពីលក្ខខណ្ឌពិបាកនៃជីវិតដូចជាពលកម្មលំបាកក្នុងស្រែចំការនិងនៅតាមការដ្ឋានសំនង់នានា។ ជាញឹកញយ ស្ត្រីច្រើនស្លាប់ក្រោយពេលបង្កើតកូនបានម្នាក់។ ដូចនេះ គេត្រូវឆ្លៀតទាញយកគុណប្រយោជន៍ពីជីវិតនិងធ្វើអ្វីៗទាំងអស់ ដើម្បីបន្តរស់រហូតដល់ការរស់ក្រោយពេលស្លាប់ទៅផងដែរ។

ម៉ូមីព្រះចៅ រ៉ាមសែសទី២ ដែលគេបានបកសំពត់រុំចេញ



## រស់នៅក្រោយពេលស្លាប់ទៅ

នៅសម័យបុរាណដ៏យូរលង់មកហើយ មានតែព្រះចៅ ផារ៉ាអុងទេ ដែលមានសិទ្ធិនិងមធ្យោបាយអាចបន្តរស់នៅបានក្រោយពេលស្លាប់ទៅហើយ។ ដើម្បីអោយវិញ្ញាណក្ខន្ធអាចរស់នៅបាន គេត្រូវថែរក្សាសាកសពនៃមនុស្សស្លាប់អោយបានគង់វង្ស គឺកុំអោយរលួយសាបសូន្យ ដោយអប់សពនិងរុំសាកសពដោយបន្ទះសំពត់តូចៗ។ គេត្រូវនាំយកសពទៅតំកល់ទុកក្នុងចេតិយជាមួយគ្រឿងសំភារៈប្រើប្រាស់ប្រចាំថ្ងៃ ដែលសពចូលចិត្ត រួមទាំងម្ហូបអាហារផង។ គេរៀបចំចេតិយ ដែលជាផ្ទះចុងក្រោយនេះយ៉ាងល្អ តុបតែងលំអដោយផ្ទាំងគំនូរ ដែលបង្ហាញពីជីវិតឋានលោកិយ និងពីជីវិតឋានអាទិទេព។ គេកសាងចេតិយអោយមានភាពរឹងមាំ ដែលអាចឋិតនៅយូរអង្វែង។

Scanned by CamScanner

## ទាំងអស់គ្នាមានសិទ្ធិរស់នៅជារៀងរហូត

កាលពី ៥ ០០០ឆ្នាំមុន ជនជាតិអេស៊ីបជាអ្នកមានធំៗបានអោយគេអប់សពខ្លួនអោយទៅជាសាកសពម៉ូមីដែរ។ ចេតិយរបស់ពួកគេ ដែលមានលក្ខណៈសំងាត់និងតុបតែងលំអដូចចេតិយរបស់ព្រះចៅផារ៉ាអុងដែរនោះ ត្រូវតែបានទទួលការការពារអោយរួចផុតពីការលួចគាស់កកាយ។ ពួកអ្នកក្របានយកសពពួកគេទៅកប់ក្បែរចេតិយពះចៅ ផារ៉ាអុង រឺចេតិយពួកអភិជន ដើម្បីអោយចេតិយទាំងនោះជួយការពារផ្នូររបស់ពួកគេ។



វិញ្ញាណក្ខន្ធ ក្នុងថាសខាងឆ្វេង មិនត្រូវធ្ងន់ជាងស្លាបបក្សីមួយទេ។ អានូប៊ីស និងសត្វកំនាចដែលជាអ្នកខាំហែកស៊ី បែរមុខទៅរកអាទិទេពអូស៊ីរីស។

## តើបេះដូងអ្នកមានទំងន់ប៉ុន្មាន?

នៅឋានខ្មោច អានូប៊ីសថ្លឹងបេះដូង (មនសិការ) របស់អ្នកស្លាប់។ បើវាធ្ងន់ជាងស្លាបសត្វម៉ាអាត ដែលជាទេវីនៃ «សច្ចធម៌» និង «យុត្តិធម៌» នោះ អ្នកស្លាប់ត្រូវសត្វកំនាចខាំហែកស៊ី និងរលាយសាបសូន្យ។ ប៉ុន្តែបើវាស្រាលជាងវិញនោះ ជីវិតអមតៈអាចចាប់ផ្តើមឡើង។

### សំណាញ់ដឹងទេថា

**ធម៌ខ្មោច**

តាមសៀវភៅខ្មោច មានតែអ្នកដែល *«បានអោយអាហារដល់អ្នកអត់ឃ្លាន អោយទឹកដល់អ្នកស្រេក អោយខោអាវដល់អ្នកអាក្រាត...»* ប៉ុននោះ ទើបអាចមានជីវិតអមតៈ។ គេនឹងបានទទួលស្វាគមន៍ពីអាទិទេពអូស៊ីរីស ដែលជាអ្នកគ្រប់គ្រងព្រលឹងក្រោយពេលស្លាប់ និងត្រួតពិនិត្យការថ្លឹងវិញ្ញាណក្ខន្ធ។

### ចេតិយទាក់ទាញពួកចោរ!

គេតែងឃើញមានការលួចគាស់កាយចេតិយ។ ជូនកាលស្ដ្រីបដែលជាភ្នាក់ងារនគរបាលចាប់បានចោរ ប៉ុន្តែគេអាចអោយប្រាក់ជាសំណូកដើម្បីអោយប៉ូលីសនោះធ្វើហាក់ដូចជាមិនឃើញអ្វីទាំងអស់ : *«ខ្ញុំបានអោយរបស់ ដែលខ្ញុំលួចគាស់បានទៅប៉ូលីស គេក៏ដោះលែងខ្ញុំមក»*។

### សាកសពម៉ូមី មានតំលៃត្រឹមកំរិត!

នៅចុងសម័យចក្រភពអេស៊ីប សាកសពសឹងតែទាំងអស់បានត្រូវអប់អោយទៅជាសាកសំពម៉ូមី : អ្នកអប់សពអោយទៅជាសាកសពម៉ូមី បានរកឃើញបច្ចេកទេសថ្មី ដែលតំរូវអោយមានចំនាយតិចជាងមុន។

**ពាក្យ** អប់ : ប្រើផលិតផលផ្សេងៗ (ទឹកអប់ អំបិលដូចជាណាត្រុងអេស៊ីប រុក្ខជាតិ...) ដើម្បីអោយស្ងួតទឹក និងរក្សាសព។ អប់ក៏មានន័យ «ធ្វើអោយមានក្លិនល្អ» ផងដែរ។ សៀវភៅខ្មោច (មើលទំព័រទី១១)។



Scanned by CamScanner

# សាងសង់ដើម្បីអោយនៅឋិតថេរ តែមិនសំរាប់ទាំងអស់គ្នាទេ

**បំនិនប្រសប់របស់ពួកស្ថាបត្យករ គុណភាពនៃគ្រឿងសំនង់ និងអាកាសធាតុវាលលំហ បានជួយថែរក្សាប្រាសាទជាច្រើនអោយនៅគង់វង្ស។ ប៉ុន្តែគេក៏ដឹងដែរថា គេហដ្ឋានរបស់ពួកអ្នកក្រីក្រមានសភាពបែបណា នៅសម័យនោះ។**

### សំណាញ់ដឹងទេថា

**ពាក្យ ពីរ៉ាមីត(ចេតិយ) មកពីភាសាក្រិច មិនមែនមកពីភាសាអេស៊ីបទេ!**

ជនជាតិក្រិច ដែលចាត់ទុកចេតិយរបស់ព្រះចៅ ខេអូប (Kheops) ជាអច្ឆរិយវត្ថុមួយក្នុងចំនោមអច្ឆរិយវត្ថុទាំង៧ក្នុងលោក បានហៅប្រាសាទទាំងនោះថា «ពីរ៉ាមីត» ពីព្រោះវាមានសណ្ឋានដូចកូនភ្នំរាងជាសាជីជ្រុង : ពីរ៉ាមី (Pyramis)។ ជនជាតិអេស៊ីប ហៅផ្នូរធំៗទាំងនោះថា«ម-រ» ពាក្យមួយ ដែលគេមិនដឹងថា តើត្រូវអានថាដូចម្ដេច។

## ភូមិកសិករ សង្កាត់សិប្បករ

ភូមិទាំងឡាយតាំងនៅលើទីទួលខ្ពស់ផុតពីទឹកជំនន់។ សំនាក ដែលគេបានរកឃើញក្នុងផ្នូរ បង្ហាញពីផ្ទះតូចៗមានតែមួយបន្ទប់សង់ពីឥដ្ឋឆៅប្រក់ស្លឹក។ សិប្បករ ដែលធ្វើការងារនៅតាមវិហារ រឺចេតិយ មានជីវភាពធូរធារជាង : ផ្ទះពួកគេមានច្រើនបន្ទប់ ស្ពាកមួយនិងបន្ទប់ក្រោមដីមួយ។

## វាំងព្រះចៅ ផារ៉ាអុង

ពេលនៅមានព្រះជន្ម ព្រះចៅ ផារ៉ាអុងគង់នៅក្នុងវាំងសង់ពីឥដ្ឋឆៅ។ ក្រោយពេលព្រះអង្គសោយទិវង្គតទៅ គេយកសាកសពព្រះអង្គទៅរក្សាទុកក្នុងផ្នូរ ដែលគេកសាងឡើងដោយចោះលុងផ្ទាំងថ្ម រឺដែលគេសង់ចេតិយរាងពីរ៉ាមីតមួយយ៉ាងធំរឹងមាំគ្របពីលើ។ កសិករសេរីរាប់ពាន់នាក់ បានសាងសង់ចេតិយទាំងនេះ ដោយប្រើបច្ចេកទេស ដែលយើងមិនបានស្គាល់ច្បាស់។ ការសាងសង់អាចប្រើពេលវេលាពី២០ទៅ៣០ឆ្នាំ។ ក្នុងរយៈពេលនេះ ពួកកម្មករបានទទួលអោយស្នាក់នៅនឹងកន្លែង ទទួលការឧបត្ថម្ភជារបស់របរ ហើយបានសំរាកមួយថ្ងៃក្នុង១០ថ្ងៃ។



Scanned by CamScanner




គេមិនដឹងថា បន្ទប់ទាំងនោះមានតួនាទីអ្វីខ្លះទេ។

## វិហារសំរាប់អាទិទេព

គេត្រូវប្រើពេលវេលាយូរណាស់ ដើម្បីសាងសង់វិហារធំៗ : ជិត ១ ០០០ឆ្នាំ សំរាប់វិហារកាណាក់។ សម័យនីមួយៗ រឺព្រះចៅ ផារ៉ាអុង មួយអង្គៗសាងសង់បន្ត និងកែប្រែអគារខ្លះៗ។ វិហារជាទីលំនៅរបស់អាទិទេពមួយអង្គ រឺច្រើនអង្គ។ នៅក្នុងព្រះវិហារ មានតាំងបដិមាព្រះអាទិទេព និងទុកសំរាប់ហែក្បួនជូនដំនើរព្រះអង្គ។

## ស្ថាបត្យករពិតៗដំបូងគេ

គេនិយាយថា រវាង៣០០០ឆ្នាំ មុនគ.ស. មនុស្សម្នាក់«បានបង្កើត» ស្ថាបត្យកម្មអំពីថ្មនិងសំនង់ចេតិយធំៗរាងសាជីជ្រុង។ គាត់មានឈ្មោះថា អ៊ីម៉ូតែប(Imhotep)។ ក្រោយមកមានអ្នកផ្សេងៗទៀតបានគូរប្លង់វិហារ និងចេតិយធំៗតាមបែបផែនរបស់ពួកគេ។ ពួកគេចេះកសាងសំនង់បំបែរទៅរកទិសដែលគេបានជ្រើសរើស ប្រើខ្សែប្រយោលនិងកែង បែងចែកការងារ គ្រោងទុកជាមុននូវសំភារៈ ដែលត្រូវប្រើប្រាស់(ខ្សែពួរ ឃ្នាស់ ឧបករណ៍...)។

### ដេរ្-អែល-មេឌីណា ភូមិបំរើសេវាអោយពួកខ្មោច

ក្នុងរយៈពេលជិត៥០០ឆ្នាំ សិប្បករ ដែលរស់នៅក្នុងភូមិនេះ បានសាងសង់ចេតិយថ្វាយព្រះចៅ ផារ៉ាអុង នៅតំបន់មួយលើត្រើយខាងឆ្វេងទន្លេនីល ទល់មុខទីក្រុងតែប។ ជាទូទៅ «កម្មករសង់ផ្នូរ» ទាំងអស់នោះចេះអាននិងសរសេរអក្សរ ប៉ុន្តែករណីនេះជាការលើកលែង។

### ចេតិយតូចធំគ្រប់ខ្នាត

ចេតិយមិននៅឯកឯង ឆ្ងាយដាច់ពីគេឡើយ។ មានចេតិយបន្ទាប់បន្សំនៅហែហមចេតិយធំៗ។ គេឃើញមានចេតិយ «ធំៗ» ចំនួនលើសពី ៤០ និងចេតិយ «បន្ទាប់បន្សំ» យ៉ាងហោចណាស់ ២០ ដែលជាផ្នូរព្រះរាជវង្សានុវង្ស។


Scanned by CamScanner

# គូរ និងឆ្លាក់ពីការពិត



រូបចំលាក់ : អេស៊ីបក្រោម(ខាងឆ្វេង) និងអេស៊ីបលើ(ខាងស្តាំ) នៅហែហមព្រះចៅ ផារ៉ាអុង

ដោយសាររូបគំនូរផាត់ពណ៌ រូបចំលាក់ និងរបស់របររកឃើញក្នុងផ្នូរ យើងអាចស្គាល់អាទិទេពអេស៊ីប ព្រះចៅ ផារ៉ាអុង ព្រមទាំងជីវិតប្រចាំថ្ងៃរបស់កសិករ ពពួកសត្វ និងរុក្ខជាតិនៃប្រទេសអេស៊ីបបុរាណទៀតផង។

## ត្រូវគោរពក្បួនខ្នាត

ក្នុងវិស័យរូបគំនូរផាត់ពណ៌ រឺចំលាក់លិប គេត្រូវគូរ រឺឆ្លាក់មុខមនុស្សមើលឃើញពីចំហៀង ភ្នែកនិងដងខ្លួនមើលឃើញពីមុខ ត្រគាកមើលឃើញប្រមាណ៣/៤ ជើងមើលឃើញពីចំហៀង។ កំពស់ត្រូវសមាមាត្រនឹងសារៈសំខាន់នៃតួអង្គ រឺវត្ថុ។ អាទិទេពត្រូវមានពណ៌ខុសៗគ្នា : រូបអូស៊ីរីសច្រើនផាត់ពណ៌ខ្មៅដូចដីល្បាប់ដែលទន្លេនីលនាំមក រឺក៏បៃតងដូចរុក្ខជាតិ ឯអាទិទេព«កំនាច» ឈ្មោះ សេត មានពណ៌ផ្កាកុលាបដូចពណ៌វាលខ្សាច់គ្មានជីជាតិ។

## សំណាញ់ដឹងទេថា

### សិប្បករថ្នាក់ខ្ពស់

អ្នកនិពន្ធមិនចុះហត្ថលេខាលើស្នាដៃរបស់ពួកគេទេ។ ប៉ុន្តែអ្នកល្បីៗបានត្រូវគេស្គាល់ច្បាស់នៅសម័យនោះ។ ពួកគេជាមន្ត្រីរាជការ ហើយថានៈប្រាប់ពីឯកទេសពួកគេ ដូចជា «មេជាងគំនូរគូរវិហារព្រះអាទិទេពអាម៉ុង» រឺ «អ្នកកាន់កន្ត្រៃ (ឧបករណ៍មុតសំរាប់កាត់ថ្ម) ក្នុងទីលាន ម៉ាអាត»។ ពួកគេមានសិទ្ធិរចនាលំអផ្នូរប្រណីតៗ។

## ចំលាក់ដូចគ្នាទៅនឹងតំរូពិតទាំងអស់ តែចំលាក់នីមួយៗមានភិនភាគខុសៗគ្នា

បើគេមើលរូបចំលាក់ គេឃើញព្រះភក្ត្ររបស់ព្រះចៅ ផារ៉ាអុង មុខរបស់តួអង្គសំខាន់ៗ រឺរបស់កសិករសាមញ្ញមានភិនភាគប្លែកៗគ្នាពីមួយទៅមួយ : វាត្រូវដូចទៅនឹងរូបរាងមនុស្សដែលគេឆ្លាក់។ ដោយសាររូបគំនូរផាត់ពណ៌និងរូបសំនាកតូចៗ ដែលគេបានរកឃើញក្នុងផ្នូរ យើងដឹងថាស្ត្រីតុបតែងសក់និងផាត់មុខដូចម្តេច កសិករស្លៀកពាក់ដូចម្តេច។ នៅក្នុងផ្នូរខ្លះ សត្វស្លាបលាបពណ៌ ដែលគេគូរក្នុងស្ថានភាពបំរុងស្ទុះហើរ ហាក់ដូចជាមានជីវិតរស់ពិតៗ។



Scanned by CamScanner

## ...ករូបភាពបង្ហាញពីជីវិតប្រចាំថ្ងៃ

...រូបគំនូរផាត់ពណ៌តាមជញ្ជាំងផ្នូរហាក់ដូចជាធ្វើអោយអ្នកស្លាប់ទៅហើយ ...នោះ អាចរស់នៅបានដូចនៅលើផែនដីដែរ។ គេអាចឃើញមានគំនូរពី ...ការប្រមូលផល ការបេះទំពាំងបាយជូរ ការបរបាញ់ ពីពួកមន្ត្រីរាជការ ...កំពុងមើលផលដំនាំ រឺបញ្ជាអោយគេវាយដំកសិករ ស្ត្រីកំពុងយំនៅពេល ...កប់ខ្មោច កម្មករកំពុងសាងសង់វិហារជាដើម។ យើងក៏អាចមើលឃើញ ...ផងដែរនូវប្រភេទត្រី សត្វស្លាប រឺដើមឈើផ្សេងៗ។



## ...ករ រឺសិប្បករ ?

...ប្រើប្រាស់ប្រចាំថ្ងៃ ដូចជាកុលាលភាជន៍ ចានក្បាន កញ្ចក់ឆ្លុះធ្វើពី ...លោហធាតុ ប្រអប់មេ្សៅ សំលៀកបំពាក់ និងគ្រឿងអលង្ការ ដែលគេបាន ...ញក្នុងផ្នូរធំៗ សុទ្ធតែល្អៗ ស្អាតៗទាំងអស់។ ប៉ុន្តែសំរាប់ជនជាតិ អេ...ស៊ីបវិញ វត្ថុនីមួយៗត្រូវតែមាន «ប្រសិទ្ធភាព» ជួយបន្តការរស់នៅ ក្រោយពីស្លាប់ទៅ ដូចគ្នានឹងរូបគំនូរផាត់ពណ៌ រឺរូបចំលាក់អីចឹងដែរ។ ពួកសិប្បករធ្វើយ័ន្តគាថាជាចំនួនច្រើនៗ ដែលគេលក់ក្នុងតំលៃថោកៗ។ ដោយហេតុនោះ ពួកអ្នកក្រក៏អាចរកទិញសំរាប់ការពារខ្លួនបានដែរ។

### ផារ៉ោអុងមួយអង្គ ដែលពុំចង់អោយគេតែងលំអព្រះកាយ

រូបគំនូរផាត់ពណ៌និងរូបចំលាក់នៅសម័យព្រះបាទអាខេណាតុនមានលក្ខណៈប្រាកដនិយមខ្លាំងជាងសម័យមុន។ ដូចនេះ យើងដឹងថា ព្រះអង្គមិនស្អាតណាស់ណាទេ តែមហេសីព្រះអង្គព្រះនាម នេភែទីទី (Néfertiti) ឆើតឆាយសំបើមណាស់!

### «ល្បិច» របស់ពួកសិល្បករ

ក្បួនខ្នាតក្នុងការឆ្លាក់ រឺគូររូបមានសភាពសាំញ៉ាំណាស់ ប៉ុន្តែជាញឹកញាប់គេតែងប្រើគំរូដែលគេគូរតាម ដោយគូសបន្ទាត់បែងជាការេ ដូចដែលយើងធ្វើសព្វថ្ងៃនេះដែរ!

រូបខាងឆ្វេង : រូបគំនូរផាត់ពណ៌លើជញ្ជាំង បង្ហាញពីពួកស្រីៗអ្នកយំ ដែលគេជួលអោយយំ ដើម្បីសំដែងទុក្ខសោកក្នុងពេលកប់ខ្មោចរបស់ពួកអ្នកមាន។

**ពាក្យ**

ចំលាក់លិប (មើលទំព័រទី១៣)។

យ័ន្តគាថា (មើលទំព័រទី១៧)។



Scanned by CamScanner

# អាថ៌កំបាំងនៃអក្សររូប

នៅតាមប្រាសាទអេស៊ីប គេឃើញមានរូបគំនូរជាច្រើន : រូបសត្វ មនុស្ស រុក្ខជាតិ ប៉ុន្តែក៏មានរូបដៃ រឺភ្នែកផងដែរ។ គឺជាអក្សររូប។ ទាល់តែមកដល់ឆ្នាំ ១៨២២ ក្រោយគ.ស. ទើបគេបានដឹងថា រូបទាំងនោះមានន័យថាដូចម្ដេច។




អក្សររូបមួយចំនួន និងតួអក្សរបារាំង ដែលត្រូវគ្នា។

## អក្សរមួយបែបមុនអក្ខរក្រម

អក្សរអេស៊ីបដំបូង ជាតំនាងវត្ថុដោយផ្ទាល់តែម្ដង : គេគូរត្រី រឺផ្ទះ ដើម្បីតំនាងអោយវត្ថុទាំងពីរនេះ រីឯរូបក្ដោងមួយប៉ោងជាតំនាងខ្យល់បក់។ អក្សរបែបនោះហៅថាអក្សរគំនិត។ ប៉ុន្តែតើគេត្រូវធ្វើដូចម្ដេច ដើម្បីសរសេរពាក្យ «សុភមង្គល» រឺ «សុខភាព»? គេប្រើសំលេង ដែលត្រូវនឹងរូបគំនូរ ដូចក្នុងបណ្ដាំរូបអីចឹង។
ជាឧទាហរណ៍  តំនាងមាត់ និងសំលេង «រ» ផងដែរ។ គំនូរបែបនេះគេហៅថា អក្សរសំលេង។ លើសពីនេះទៅទៀត ក្នុងភាសាអេស៊ីប តួអក្សរដូច «ហ» ត្រូវអានតាមពីរបែបខុសពីគ្នា។

### សំណាញ់ដឹងទេថា

**ភាសាអេស៊ីប ជាភាសាដែលគេប្រើនៅក្នុងតំបន់ជាច្រើន**

គេប្រើអក្សររូបនៅប្រទេសអេស៊ីប ប្រទេសស៊ូដង់ តំបន់មាត់សមុទ្រក្រហម និងនៅមជ្ឈិមបូព៌ា។ សិលាចារឹកជាអក្សររូបចុងក្រោយបំផុត បានត្រូវចារឹកនៅថ្ងៃ ២៤ ខែសីហា ឆ្នាំ ៣៩៤ ក្រោយគ.ស. នៅឯវិហារមួយលើកោះ ភីឡាអេ ក្នុងទន្លេនីល។

## នៅពីក្រោយអក្សររូប

អក្សររូបមានចំនួនជាង២ ៥០០តួខុសៗគ្នា ដែលគេត្រូវអានពីលើចុះក្រោម ពីស្ដាំមកឆ្វេង រឺពីឆ្វេងទៅស្ដាំ! ហើយគំនូរ



Scanned by CamScanner

...អស់នោះសុទ្ធតែជាព្យញ្ជនៈ។ ដូចនេះគេត្រូវបន្ថែមគំនូរមួយទៀត ...ដើម្បីសំគាល់ន័យត្រឹមត្រូវរបស់ពាក្យ គឺដូចជាយើងសរសេរ «រ-ត» ...រាប់ថា «រូត» រឺក៏ថា «រឹត» !

## ...ក្សររូបកែសំរួល

...ឆ្នាំរយុរប៉ុន្មាន ពួកស្រ្គីបបានកែលំអធ្វើអោយអក្សរមានលក្ខណៈងាយស្រួល ដើម្បីសរសេរអោយបានលឿន ជាពិសេសសរសេរលើប៉ាពីរុស។ ...ពួកគេសរសេរអត្ថបទ រឺធ្វើបញ្ជីដោយប្រើដើមត្រែងច្នៃធ្វើជាជក់ហៅថា ...កាឡាម និងទឹកខ្មៅពណ៌ខ្មៅ។ ប៉ុន្តែគេប្រើទឹកខ្មៅពណ៌ក្រហមសំរាប់កែ ...កិច្ចការកូនសិស្ស! ពួកស្រ្គីបមានសារៈសំខាន់ណាស់! ព្រោះមានតែពួកគេទេ ដែលចេះអាន និងសរសេរអត្ថបទសព្វបែបយ៉ាង។

## ...អឺរ៉េកា!



...គឺជាពាក្យ ដែលជនជាតិបារាំងម្នាក់ឈ្មោះ សំប៉ូល្យ៉ុង (Champollion) អាចស្រែកឧទានឡើងដោយរីករាយ : នៅឆ្នាំ ១៨២២ លោកជាជនទីមួយ ដែលបានអានអក្សររូបដាច់ ដោយសារតែសិលាចារឹកមួយផ្ទាំង ដែលគេយកមកពីទីក្រុងរ៉ូសែត។ នៅលើផ្ទាំងសិលានោះ មានចារអត្ថបទជា៣ភាសា ដោយបកប្រែពីភាសាមួយទៅភាសាមួយ ហើយសរសេរជាអក្សររូប អក្សរក្រិច និងអក្សររូបកែសំរួល។



គេអាចមើលផ្ទាំងសិលា «មកពីទីក្រុងរ៉ូសែត» នៅឯសារមន្ទីរ សំប៉ូល្យ៉ុង ជីភិសៀច ក្នុងប្រទេសបារាំង។

### អក្សរប្រកបដោយគ្រោះថ្នាក់

អក្សររូបពិតៗ ក៏ជាសញ្ញាពិសិដ្ឋផងដែរ ហើយប្រហែលជាដោយហេតុនោះ ទើបវាមិនបានផ្លូវសោះ ក្នុងរយៈពេល ៣ ០០០ឆ្នាំ! នៅក្នុងផ្នូរ «រូបពស់» ដែលជាអក្សររូប បានត្រូវចងភ្ជាប់នឹងដី ដើម្បីកុំអោយវាចឹកអ្នកស្លាប់!។



### ពីគំនូរ ទៅជាអក្សរ ដែលគេសំរួលអោយងាយ

ក្អែងបោង គឺខ្យល់បក់ ប៉ុន្តែដើម្បីសរសេរអោយបានលឿន គេបានកែវាអោយងាយបន្តិចម្តងៗ ឈានទៅជារូបតូចនេះ។

រូបខាងឆ្វេង : លោកសង់ប្រង់ស្វ័រ សំប៉ូល្យ៉ុង (១៧៩០–១៨៣២)

**ពាក្យ** ប៉ាពីរុស (មើលទំព័រទី៩)។



Scanned by CamScanner

# ដំណើរនៃពេលវេលា






Scanned by CamScanner

# ប្រទេសអេស៊ីបនៅសតវត្សទី៣ មុនគ.ស.






Scanned by CamScanner



# ដើរតាមដានអេស៊ីប

អរិយធម៌អេស៊ីបបានរលត់បាត់បង់ទៅតាំងពីយូរលង់មកហើយ ប៉ុន្តែអរិយធម៌នេះនៅតែធ្វើអោយយើងរំភើប និងទាក់ទាញចិត្តយើង។ ជានិច្ចកាល អរិយធម៌អេស៊ីបតែងបណ្តាលចិត្តយើងអោយចង់ប្រឌិតរឿងរ៉ាវផ្សេងៗ មានតាំងពីការលួចគាស់របស់របរក្នុងផ្នូររហូតទៅដល់ការគួរជាឆាកនិទាន។

### សំណាញ់និងមេថា

**អាថ៌កំបាំងសំរាប់សើច...រឺសំរាប់ធ្វើអោយភ័យខ្លាច!**

ពីផាករូបភាព(រឿងចារីធំរបស់ផារ៉ាអុង ដំនើរផ្សងព្រេងរបស់តាំងតាំង) ទៅដល់ខ្សែភាពយន្ត(ម៉ូមី) រឿងភូតភរគួរអោយភ័យខ្លាចតែងទទួលបានជោគជ័យ។ តែគេលែងប្រើធូលីម៉ូមីដើម្បីព្យាបាលជំងឺក្អកដូចនៅស.វ.ទី១៧ ទៀតហើយ!

### ម៉ូតអេស៊ីបនៅប្រទេសអ៊ីតាលី

ជនជាតិរ៉ូមក្នុងសម័យព្រះបាទ ជូល សេសា(Jules César) និងព្រះបាទអូគុស(Auguste)បានទទួលយកអាទិទេពអេស៊ីប នាំយកសិលាស្តម្ភមកពីអេស៊ីប កសាងពីរ៉ាមីតបានពីរនៅក្រុងរ៉ូម និងដាក់តាំងរូបចំលាក់សត្វស្វាំងលំអសួនច្បាររបស់ពួកគេ។ នៅមជ្ឈិមសម័យ គេប្រើបដិមាទាំងនោះជាគំរូដើម្បីឆ្លាក់រូបសត្វតោ!

### មុនសម័យ... នៃអេស៊ីប

នៅស.វ.ទី១៦ គេរកឃើញអេស៊ីបជាថ្មីទៀត តាមរយៈអក្ខបទក្រិច និងឡាតាំង : សិលាស្តម្ភលេចឡើងជាថ្មីនៅទីក្រុងរ៉ូម នៅមុខព្រះវិហារបាស៊ីលិចសាំងព្យែ។ នៅស.វ.ទី១៧ គេខិតខំអានអោយយល់អក្សររូប ហើយនៅស.វ.ទី១៨ គេធ្វើដំនើរទៅដល់ទីកន្លែងផ្ទាល់ដើម្បីទស្សនា និង



Scanned by CamScanner

កោតសរសើរវិហារ វីពីរ៉ាមីត។ *«រយៈពេល៤០ស.វ.សំលឹងមើលមកអ្នកពីលើកំពូលពីរ៉ាមីតទាំងនេះ»* អនាគតព្រះបាទណាប៉ូឡេអុង ឧទានឡើង ពេលគាត់កំពុងស្ញើចសរសើរសំនង់ទាំងនោះ (មើលគំនូរទំព័រ២៨)។

## បូណាប៉ាត គ្រាដំបូងនៃការស្រលាញ់ជាប់ចិត្តរបស់យើងចំពោះអេស៊ីប

ពួកអ្នកប្រាជ្ញ ដែលត្រលប់មកពីប្រទេសអេស៊ីបវិញជាមួយបូណាប៉ាត (១៧៩៩) បាននាំយកមកនូវគំរូសំរាប់ស្ថាបត្យករ ជាងតុទូ រហូតដល់អ្នកស្លចានឆ្នាំងផងដែរ! របកគំហើញផ្នូររបស់ទូតង់ខាម៉ុន ក្នុងឆ្នាំ ១៩២២ ជំរុញម៉ូតនេះសាជាថ្មីម្តងទៀត។ ពួកសិល្បករ (ជាងចំលាក់ ជាងទង ជាងលំអនិងអ្នកផលិតខ្សែភាពយន្ត...) យកគំនិតតាមគំរូទាំងនេះ។ សព្វថ្ងៃ គេអាចមើលប្រវត្តិសាស្រ្តបានតាមរយៈអក្សររូប ហើយទាំងអស់គ្នាក៏អាចមើលឃើញសោភណភាពនៃអត្ថបទល្អៗរបស់អ្នកនិពន្ធអេស៊ីបផងដែរ។

ចៀមផប

## សិលាស្តម្ភ និងពីរ៉ាមីតមាននៅគ្រប់ទីកន្លែង!

សព្វថ្ងៃនេះ នៅក្នុងទីធ្លាសារមន្ទីរល្វូនៅទីក្រុងប៉ារីស គេឃើញមានពីរ៉ាមីតល្អឆើតឆាយមួយធ្វើពីកញ្ចក់ ឯនៅទីក្រុងឡាស-វ៉េកាសនៃសហរដ្ឋអាមេរិច គេបានសង់សណ្ឋាគារមួយមានរាងជាពីរ៉ាមីត។ ប៉ុន្តែនៅក្នុងទីក្រុងជាច្រើន គេអាចប្រទះឃើញសំនង់តូចៗមានរាងជាពីរ៉ាមីតច្រើនទៀត ដែលភាគច្រើនសង់ពីកញ្ចក់... អេស៊ីបនៅតែបន្តធ្វើជាគំរូរបស់យើង។ នៅប្រទេសអេស៊ីប មានសល់សិលាស្តម្ភចំនួនតែ៥ប៉ុននោះ ដែលនៅឈរនៅឡើយ ប៉ុន្តែគេឃើញមានសិលាស្តម្ភចំនួនជាង១៥នៅទ្វីបអឺរ៉ុប និងនៅទ្វីបអាមេរិច។



**សិលាស្តម្ភលុកស៊ (Louqsor) តាំងនៅទីក្រុងប៉ារីស ក្នុងឆ្នាំ ១៨៣៦។ គេអាចមើលឃើញសិលាស្តម្ភនេះនៅឡើយ នៅទីលានឡាកុងគ័ត។**

### ម៉ូតចំលងពីគំរូអេស៊ីប

នៅសតវត្សទី២០ ពួកជាងទង និងពួកអ្នកធ្វើទឹកអប់ បានយកគំនិតតាមអេស៊ីប: បន្តោងនៅដើមទ្រូង រឺទឹកអប់ «អាថ៌កំបាំងសត្វស្វាំង» ដែលគេដាក់លក់ក្នុងផើងកាណូប បានទទួលការចូលចិត្តពីសំនាក់អ្នកលេងខ្ទួន។

### រស់នៅ «តាមបែបអេស៊ីប»

នៅរវាងឆ្នាំ ១៨០០-១៨១៥ គេបានធ្វើនាឡិកាប៉ោលមានរាងដូចវិហារអេស៊ីប កៅអីដូចកៅអីព្រះចៅ ផារ៉ាអុង ហើយអក្សររូបទទួលការពេញនិយមណាស់: គឺជារចនាបថ «អេស៊ីបវិលវិញ»។

**ពាក្យ**

បន្តោងនៅដើមទ្រូង: បន្តោងធំសំប៉ែត ដែលគ្របដើមទ្រូង។

ផើងកាណូប: ផើងធ្វើអំពីដីរឺថ្ម មានផ្តុករាងដូចក្បាលសំរាប់ដាក់ថ្លើម សួត ក្រពះ រឺពោះវៀនរបស់សាកសពដែលគេអប់អោយទៅជាម៉ូមី។



Scanned by CamScanner

# ប្រវត្តិសាស្ត្រ នៅក្រោមខ្សាច់



នៅមានរបស់ច្រើនណាស់ កប់នៅក្រោមខ្សាច់ ក្នុងសមុទ្រ រឺក្នុងអត្ថបទ ដែលជនជាតិអេស៊ីបបានបន្សល់ទុក ហើយ ដែលយើងត្រូវស្រាវជ្រាវរកយកមកសិក្សា។ ហេតុដូចនេះហើយ ទើបពួកអ្នកអេស៊ីបវិទ្យាបានអំពាវនាវរកជំនួយ ពីអ្នកឯកទេសនានា ដូចជាអ្នកបុរាណវត្ថុវិទ្យា អ្នកមុជក្នុងសមុទ្រ វិស្វករ និងនីតិពេទ្យ។

របកគំហើញផ្នូរព្រះចៅ ទូតង់ខាម៉ុន ក្នុងឆ្នាំ ១៩២២ នៅចំពោះមុខអ្នកបុរាណវត្ថុវិទ្យា កាកទែ (Carter)

### សំណាញ់ដឹងទេថា

**មុខរបរមួយពិបាក**

ជាការពិបាក និងត្រូវចំនាយពេលយូរ ទើបក្លាយជាអ្នកអេស៊ីបវិទ្យា។ គេត្រូវរៀនប្រវត្តិសាស្ត្រ ចេះធ្វើកំនាយ ចេះអានអក្សររូប... សរុបទៅ ត្រូវរៀនសូត្រយូរ តែគេអាចធ្វើដំនើរទៅអេស៊ីប អានសៀវភៅរឺចាប់ផ្តើមសិក្សាអក្សររូប និងសិល្បៈអេស៊ីបសំរាប់កំសាន្ត ដូចជានៅសាលាលូ។ នៅមានអ្វីៗច្រើនទៀត ដែលត្រូវរកអោយឃើញ និងសិក្សា... ជាការងារមួយសំរាប់អ្នក?

### បុរាណវត្ថុវិទ្យាជាជំនួយដល់ប្រវត្តិវិទ្យា

អត្ថបទសរសេរដោយជនជាតិអេស៊ីប ពុំបាននៅគង់វង្សទាំងអស់ទេ ហើយអត្ថបទទាំងនោះ ក៏ច្រើនតែនិយាយពីព្រះចៅ ផារ៉ាអុង ពីព្រះអាទិទេពនិងពីអ្នកស្លាប់។ កាលណាស្ត្រីបម្នាក់សរសេរពីជីវិតកសិករ គាត់តែងសរសេរក្នុងក្រសែភ្នែកគាត់ជាស្ត្រីប។ គាត់សំដែងសេចក្តីមើលងាយបន្តិច ហើយចង់បង្ហាញអោយពួកសិស្សរបស់គាត់មើលឃើញថា មានអ្វីនឹងរង់ចាំពួកគេ កាលណាពួកគេមិនខំរៀនសូត្រ! ពួកអ្នកបុរាណវត្ថុវិទ្យា ដែលធ្វើការតាមបែបវិទ្យាសាស្ត្រ និងចេះប្រុងប្រយ័ត្នដូចភ្នាក់ងារប៉ូលីសនោះ អាចចូលជ្រៅទៅជិតជីវិត «ពិតៗ» របស់ជនជាតិអេស៊ីបជាជាងពួកស្ត្រីប។

### ប្រយ័ត្នចំពោះការយកពត៌មាន !

ការដ្ឋានបុរាណវត្ថុវិទ្យាធំៗ ជាពិសេសការដ្ឋានក្នុងសមុទ្រ ទាមទារអោយមានចំនាយច្រើន ហើយពួកអ្នកបុរាណវត្ថុវិទ្យាតែងស្វះស្វែងរកជំនួយឧបត្ថម្ភ។ ប៉ុន្តែអ្នកឧបត្ថម្ភចូលចិត្តអោយគេនិយាយពីខ្លួនឯង នៅក្នុងការផ្សព្វផ្សាយតាមទូរទស្សន៍។ ដោយហេតុនេះ ជួនកាលគេផ្សាយ



Scanned by CamScanner

ពត៌មានអំពីរបកគំហើញចំលែកអស្ចារ្យ ដែលធ្វើអោយកើតមានគំនិតស្រើបស្រាល...ប៉ុន្តែមិនពិតទាល់តែសោះ។ ជាឧទាហរណ៍ នៅទីក្រុងអាឡិចសង់ឌ្រី គូប្រជែង២ក្រុមផ្សាយថារកឃើញសើនដ៏ល្បីល្បាញ...តែនៅទីកន្លែងផ្សេងគ្នា!

## សាកសពម៉ូមីនិយាយ

វិទ្យាសាស្ត្រនីតិពេទ្យអាចផ្តុំបច្ចេកទេសអប់សាកសពឡើងវិញ ជាពិសេសដោយសារសាកសពម៉ូមីជាច្រើន ដែលគេបានរកឃើញក្នុងផ្នូរធំៗ នាពេលចុងក្រោយនេះ។ តាមការស្រាវជ្រាវលើសាកសពម៉ូមីទាំងនោះ យើងបានដឹងថា ពួកអេស៊ីបមានជំងឺអ្វី ស្លាប់នៅអាយុប៉ុន្មាន ស្លាប់ដោយសារអ្វីដូចជា ស្លាប់ដោយគ្រោះថ្នាក់ ឬដោយបទឧក្រិដ្ឋជាដើម។

## ប៉ុន្តែគេពុំអាចដឹងអ្វីៗ បានសព្វគ្រប់ទេ

ទោះបីនៅប្រទេសអេស៊ីបគេធ្វើការងារទាំងអស់នេះ ព្រមទាំងរកឃើញអ្វីថ្មីៗជារៀងរាល់ថ្ងៃក៏ដោយ ក៏គេនឹងពុំអាចចូលតួជាជនអេស៊ីប នាឆ្នាំ ៤000 មុនគ.ស. ហើយនឹកគិតដូចជនអេស៊ីបពិតៗនោះបានដែរ។ ប៉ុន្តែគេអាចផ្តុំរបៀបរស់នៅប្រចាំថ្ងៃរបស់ជនអេស៊ីបឡើងវិញបាន។



### ហ្វឺ! បន្ទាចខ្ញុំមក!

គេបាននិយាយពីបណ្តាសាសាកសពម៉ូមី : សព ដែលបានត្រូវគេរំខានមិនអោយបានសំរាកស្រួលនឹងធ្វើការសងសឹកវិញ។ ប៉ុន្តែរឿងទាំងនេះ សុទ្ធតែជារឿងព្រេងនិទានទេ! ជាឧទាហរណ៍ ពួកអ្នកបុរាណវត្ថុវិទ្យា ដែលបានរកឃើញផ្នូរទូតង់ខាម៉ុន សុទ្ធតែទទួលមរណភាពតាមធម្មជាតិក្រោយរបកគំហើញនោះយ៉ាងយូរ លើកលែងតែអ្នកដែលមានជំងឺមុននោះទេ។

**ពាក្យ**

សើន : ប៉មខ្ពស់ៗ ដែលគេសង់ សំរាប់ដាក់ភ្លើងជាសញ្ញានាំផ្លូវនាវានៅពេលយប់។
សើននៅក្រុងអាឡិចសង់ឌ្រី : អច្ឆរិយវត្ថុមួយក្នុងចំនោមអច្ឆរិយវត្ថុពិភពលោកទាំង៧ ក្នុងសម័យបុរាណ។
អប់ (មើលទំព័រទី១៩)។

ការដ្ឋានកំនាយនៅអេស៊ីប នាពេលបច្ចុប្បន្ន



Scanned by CamScanner

គង្ទន់អង្គ W ទំរុ 1 ទំព្រែប... 0 = 1

# សាកល្បងរកចម្លើយ

...នសៀវភៅ «ខ្ញុំចង់ដឹង» នេះចប់ហើយ តើសំលាញ់ចាំបានអ្វីខ្លះ? សំនួរទាំងនេះ អាចជួយអោយសំលាញ់ធ្វើការសាកល្បងលើចំនេះដឹងរបស់ខ្លួន។ ប្រយ័ត្នណា! ជួនកាល អាចមានចំលើយច្រើន។

*ចំលើយ : ទំព័រ៣៣*

1 **ទឹកទន្លេនីលឡើង ៖**

ក. ដោយសារទំនប់។

ខ. ដោយសារភ្លៀងនៅតំបន់អេត្យូពី។

គ. ពីព្រោះមានភ្លៀងច្រើននៅអេស៊ីប។

2 **កាលណាទឹកទន្លេនីលឡើងតិច ៖**

ក. មានដីល្បាប់។

ខ. ទុរ្ភិក្សកើតឡើង។

គ. គេរីករាយសប្បាយចិត្ត។

3 **ព្រះចៅ ផារ៉ាអុង ជា ៖**

ក. អនុជអាទិទេពតំនាងព្រះអាទិត្យ។

ខ. បុត្រាអាទិទេពតំនាងមេឃ។

គ. បុត្រាអាទិទេពតំនាងព្រះអាទិត្យ។

4 **នៅអេស៊ីប គេបង់ពន្ធ ៖**

ក. ជាស្រូវសាលី។

ខ. ជាប្រាក់។

គ. ជាខ្សែរធ្វើពីសំបកខ្យងខ្ចៅ។

5 **នៅប្រទេសអេស៊ីប ៖**

ក. ទាំងអស់គ្នាចេះសរសេរ។

ខ. មានតែផារ៉ាអុងទេ ដែលចេះសរសេរ។

គ. មានតែពួកស្គ្រីប ពួកបព្វជិតនិងព្រះចៅផារ៉ាអុងទេ ដែលចេះសរសេរ។

6 **ព្រះបដិមាអាទិទេព ៖**

ក. ទទួលតង្វាយជាចង្ហាន់ពីពួកបព្វជិត។

ខ. នៅកន្លែងលាក់បំពួន។

គ. ត្រូវគេកប់ក្នុងដី រៀងរាល់ឆ្នាំ។

7 **កម្មករ ដែលសាងសង់ពីរ៉ាមីតជា ៖**

ក. កសិករសេរី។

ខ. អ្នកទោស។

គ. ទាសករ។

8 **អ៊ីម៉ូតែបបានបង្កើតពីរ៉ាមីតនៅរវាងឆ្នាំ ៖**

ក. ៥០០ មុនគ.ស.។

ខ. ៣០០០ មុនគ.ស.។

គ. ១០០០ មុនគ.ស.។

9 **អក្សររូបតាង ៖**

ក. វត្ថុមួយ រឺសត្វមួយ។

ខ. សំលេងមួយ។

គ. ស្រៈទាំងអស់។



Scanned by CamScanner

# សិទ្ធិលើរូបភាព

Hun Sen Library
K010333

**គំនូរដោយ**

ទំព័រ4 : © ឃុន សុវណ្ណារិទ្ធ

ទំព័រ1, 3, 4-5, 11, 12, 14-15, 16-17, 19 : © Régis Mac

**រូបថតដោយ**

ក្របសៀវភៅ : © Bridgeman Giraudon, P. Sorgue / ទំព័រ3 : © R. Clavaud / ទំព័រ6 : © R. Clavaud / ទំព័រ7 : © Isocèle / ទំព័រ8 : © F. Guillaumet / ទំព័រ8-9 : © B. Guillemard / ទំព័រ10 : © Lauros-Giraudon / ទំព័រ13 : © Giraudon / ទំព័រ18 : © Giraudon / ទំព័រ20 : © R. Clavaud / ទំព័រ21 : © B. Douin / ទំព័រ22 : © P. Sorgue / ទំព័រ23 : © Giraudon / ទំព័រ24 : © F. Guillaumet / ទំព័រ25 : © Harlingue-Viollet, Collection Viollet, F. Guillaumet / ទំព័រ26-27 : © Isocèle, P. Sorgue / ទំព័រ28 : La bataille des Pyramides, Watteau, Musée des Beaux-Arts, Lille © E. Lessing-AGK Paris / ទំព័រ29 : © Corbis-Sygma / ទំព័រ30 : © Collection Viollet / ទំព័រ31 : © R. Clavaud

CATALOGED IN ALEPH
No.: 31134
Date: 31_07_13

# ការថ្លែងអំណរគុណ

យើងខ្ញុំសូមអរគុណជាពិសេស ចំពោះក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និង សំភារៈឧបទេសរប ក្រសួងអយក។ ចំពោះក្រសួងការបរទេសបារាំង (Ministère français de[...]ires étrangères) ដែលបានជួយទិញសិទ្ធិសំរាប់ការបោះពុម្ពពី Mila[...]:មជ្ឈមណ្ឌលភាសាបារាំង (Centre cultu[...] français) ដែលបាន[...]ៀវភៅមុនពេលបោះពុម្ព។ សៀវភៅនេះទទួលឧបត្ថម្ភពីកូនចៅរបស[...]ទ័ន ដឺ សាំងតិចស៊ុយប៉េរី (ouvrage hon[...]ré d'une subvention de la succes[...]toine de Saint-Exupéry)។

**ចំលើយ**

1-ខ/2-គ/3-ក/4-ក/5-គ/6-ក/7-ក/8-ខ/9-កនិងខ

SIPAR

© Éditions SIPAR 2003

ផ្ទះលេខ 9 ផ្លូវ 21
ទន្លេបាសាក់ ចំការមន
ភ្នំពេញ – កម្ពុជា
ទូរស័ព្ទ : (855-23) 216 001
ទូរសារ : (855-23) 987 908
siparedition@online.com.kh

រាល់ការចំលងទាំងអស់ ឬការចំលងផ្នែកណាមួយនៃសៀវភៅនេះ ទោះបីជាតាមរបៀបណាក៏ដោយ ដោយគ្មានការយល់ព្រមពីអង្គការស៊ីប៉ា (SIPAR) គឺខុសច្បាប់ និងត្រូវ[...]នទោ សិទ្ធិចំលង និងបកប្រែចំពោះគ្រប់ប្រទេសទាំងអស់។

បោះពុម្ពនៅប្រទេសកម្ពុជា
ដោយរោងពុម្ព
3D Graphics Publishing
Imprimé au Cambodge
Printed in Cambodia

Scanned by CamScanner

តំលៃ 3 500 រៀល

# សៀវភៅនៃ ក្រុមសៀវភៅ ខ្ញុំចង់ដឹង ដែលបានចេញផ្សាយរួចហើយ ៖













ធ្នូ ២០០៣





សៀវភៅទាំងពីរនេះជា
មគ្គុទេសក៍ដ៏ល្អសំរាប់
ជួយកសាងអនាគតអ្នក

Éditions SIPAR - ផ្ទះលេខ 9 ផ្លូវ 21 ទន្លេបាសាក់ ចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទ : (855-23) 216 001 - ទូរសារ : (855-23) 987 908
Email : siparedition@online.com.kh

Scanned by CamScanner